មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ( អង្គការសេដាក) និងបណ្តាញកសិករ និងធម្មជាតិ (FNN) សហការជាមួយបណ្តាញសកម្មភាពថ្នាំពុលអាស៊ីប៉ាស៊ីហ្វិក (PAN AP) បានរៀបចំធ្វើសន្និសីទកាសែតមួយ ស្តីអំពី ទិវារអត់ស្បៀងពិភពលោក នៅថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០០៨ នៅការិយាល័យអង្គការសេដាក ក្រុងភ្នំពេញ។ អ្នកចូលរួមចំនួន ៦២ នាក់ ( ស្ត្រី ១០ នាក់) រួមមានតំណាងកសិករ បុគ្គលិកអង្គការសេដាក និងអ្នកកាសែតជាតិ អន្តរជាតិ តំណាងឱ្យស្ថាប័ន កាសែត ទស្សនាវដ្តី វិទ្យុ និងទូរទស្សន៍ ចូលរួមនៅក្នុងសន្និសីទកាសែតនេះ ។ បណ្ឌិត **យ៉ង សាំងកុមារ** ប្រធានអង្គការសេដាក និងតំណាងកសិករមកពីខេត្តមួយចំនួនបានធ្វើបទបង្ហាញស្តីអំពីៈ



- ស្ថានភាពទូទៅនៃទិវាអត់ស្បៀងពិភពលោក វិបត្តិស្បៀងពិភពលោក និងនៅកម្ពុជា
- បទពិសោធន៍ តើកសិករត្រូវធ្វើយ៉ាងម៉េចដើម្បីមានស្បៀងហូបគ្រប់គ្រាន់
- បញ្ហាស្បៀងឡើងថ្លៃ និងបញ្ហារបស់ស្ត្រី
- ការលក់ដីស្រែរបស់កសិករ
- ផលប៉ះពាល់នៃការប្រើប្រាស់ និងពឹងអាស្រ័យលើជីគីមីរបស់សហគមន៍
- អត្ថប្រយោជន៍ និងវិធីផលិតពូជបានល្អជាដើម ។ល ។

បន្ទាប់ពីបទបង្ហាញដោយសង្ខេបរបស់តំណាងកសិករ និងបណ្ឌិត **យ៉ង សាំងកុមារ** រួចមក អ្នកកាសែតជាតិ និងអន្តរជាតិបានសួរសំណួរទៅកាន់បណ្ឌិត **យ៉ង សាំងកុមារ** ក៏ដូចជាតំណាងកសិករជុំបញ្ហាវិបត្តិស្បៀង និងទិវាអត់ស្បៀងនៅកម្ពុជា ។ មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ( អង្គការសេដាក) និងបណ្តាញកសិករ និងធម្មជាតិ (FNN) ក៏បានចេញនូវសេចក្តីថ្លែងការណ៍រួមមួយដែលមាន ៩ ចំនុច អំពាវនាវដល់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ និងបានធ្វើការចែកជូនដល់អ្នកកាសែតក៏ដូចជាកសិករ។ នៅពេលរសៀល ទិវានេះបានបន្តដោយធ្វើការផ្សាយបន្តរផ្ទាល់កិច្ចពិភាក្សាស្តីអំពីទិវាអត់ស្បៀងពិភពលោក នេះ តាមរលកធាតុអាកាសវិទ្យុមណ្ឌលព័ត៌មានស្ត្រីកម្ពុជា អេហ្វអឹម ១០២ មេកាហឺត វេលាម៉ោង ២:៣០ ដល់ ម៉ោង ៤:០០ ល្ងាច។

ជាលទ្ធផលប្រជាពលរដ្ឋជាច្រើនមកពីខេត្តក្រុងផ្សេងៗគ្នា បានទូរស័ព្ទចូលសួរសំនួរ និងលើកជាសំណូមពរ ផ្ទាល់ជូលដល់រដ្ឋាភិបាល ។ មិនតែប៉ុណ្ណោះ អត្ថបទព័ត៌មានជាច្រើន ត្រូវបានកាសែតជាតិ និងអន្តរជាតិ ធ្វើការចុះផ្សាយ និងផ្សព្វផ្សាយតាមរលកធាតុអាកាស។

# ទិវាពិភពលោកអត់ស្បៀងៈសេដាកអះអាងថាកម្ពុជាខ្វះស្បៀងប្រមាណមួយសែនគ្រួសារ



*សន្និសីទកាសែតស្តីពីទិវាអត់ស្បៀងអាហារពិភពលោក (រូបថតៈមួល សម្បត្តិ)*

ភ្នំពេញៈ សព្វថ្ងៃនេះមានប្រជាជនស្រេកឃ្លានច្រើនជាងពេលកន្លងមក ពោលគឺប្រមាណ១៥០លាននាក់ ។ នេះបើតាមការអះអាងរបស់លោកអាន់តូនីអូ ទូរេស សហប្រធានសម្ព័ន្ធប្រជាជនស្តីពីអធិបតេយ្យភាពស្បៀង ដែលបានលើកឡើងក្នុងឱកាស «ទិវាអត់ស្បៀងពិភពលោក» ដែលប្រារព្ធធ្វើឡើងនាថ្ងៃទី១៦ខែតុលានាឆ្នាំ២០០៨ ។

លោកបណ្ឌិត យ៉ង សាំងកុមារ ប្រធានអង្គការសេដាកក៏បានលើកឡើងក្នុងសន្និសីទកាសែតនៅថ្ងៃ១៦ខែតុលា នាស្នាក់ការរបស់អង្គការនៅទីក្រុងភ្នំពេញថា ប្រជាជនកម្ពុជាប្រហែលមួយសែនគ្រួសារ ត្រូវជាកន្លះលាននាក់ ត្រូវខ្វះស្បៀងបរិភោគ ។ ឆ្នាំ២០០៨នេះ កម្ពុជាយើងក៏ជួបប្រទះនូវបញ្ហាស្បៀងអាហារដែរនេះ ដោយសារកន្លងមកមានការឡើងថ្លៃខ្ពស់នៃស្បៀងនៅលើពិភពលោក ។ បើតាមលោកយ៉ង សាំងកុមារបានឱ្យដឹងថា សេដាកបានធ្វើការជាមួយសហគមន៍កសិករចំនួន២.០០០ភូមិក្នុងទូទាំងប្រទេស បានរកឃើញថា ៥០ភាគរយឬពាក់កណ្តាលនៃកសិករដែលធ្វើស្រែមិនអាចផលិតស្រូវបរិភោគប្រចាំឆ្នាំគ្រប់គ្រាន់ទេ ។ ក្នុងគ្រួសារកសិករដែលធ្វើស្រែ១,៨លានគ្រួសារ ក្នុងនោះមាន៥ទៅ៦សែនគ្រួសារមិនអាចផលិតស្បៀងបរិភោគគ្រប់គ្រាន់ ។ មាន៨ម៉ឺនគ្រួសារអាចទិញអង្ករបរិភោគលើសពីមួយខែនៅចុងរដូវវស្សារបស់ខ្លួន ។

សេដាករកឃើញថា នេះគឺបណ្តាលមកពីកត្តាដីធ្លីផលិតស្បៀងអត់កើន ។ ថ្វីត្បិតតែផ្ទៃដីកសិកម្មទូទាំងប្រទេសមានទំហំ៦លានហិកតាក៏ដោយ ក៏ការផលិតស្បៀងអាហារបច្ចុប្បន្ននេះបានប្រមាណតែជាង៣លានហិកតា ។ កត្តាមួយទៀតគឺការខ្វះទឹកភ្លៀងឬភ្លៀងយឺត ហើយប្រព័ន្ធស្រោចស្រពអាចសម្រេចបានតែ៤០ភាគរយនៃផ្ទៃដីប៉ុណ្ណោះ ។ នៅខេត្តតាកែវ និងខេត្តកំពង់ស្ពឺកសិករ៨០ភាគរយ មានផ្ទៃដីស្រែតិចជាងមួយហិកតា ក្នុងមួយគ្រួសារៗ ។ កសិករប្រមាណ៣០ភាគរយមានដីស្រែតិចជាងកន្លះហិកតាក្នុងមួយគ្រួសារៗ ។

អ្នកស្រីសារ៉ូ វេជធីឌី រ៉េនហ្គាយ នាយកប្រតិបត្តិបណ្តាញសកម្មភាពថ្នាំពុលអាស៊ីប៉ាស៊ីហ្វិកបានលើកឡើងថា ទិវាអត់ស្បៀងអាហារនាថ្ងៃទី១៦ខែតុលានេះ គឺជាសារមួយដើម្បីបង្ហាញពីយុទ្ធសាស្ត្ររបស់ប្រជាជនដើម្បីដោះស្រាយវិបត្តិស្បៀងអាហារ ។ ទិវានេះបង្កើតឱ្យមានការយល់ដឹងជាសាធារណៈ អំពីមូលហេតុចម្បងនៃវិបត្តិស្បៀងអាហារ ។ ធ្វើសកម្មភាពដើម្បីបង្កើនសំឡេងប្រជាជនប្រឆាំងនឹងគោលនយោបាយសេរីថ្មី និងផលប៉ះពាល់របស់វា ។

កសិករធឿន សុផល តំណាងឱ្យសហគមន៍ប្រចាំស្រុកដងទង់ ខេត្តកំពត ដែលបានចូលរួមក្នុងទិវានេះបានប្រាប់ថា កសិករខេត្តកំពតមួយចំនួនជួបការលំបាកក្នុងការទិញជីគីមីពីប្រទេសវៀតណាមមានតម្លៃខ្ពស់ ។ ដល់ពេលបានផលស្រូវ លក់ស្រូវវិញសងតែថ្លៃជីគីមីស្ទើរតែមិនបានផង ។ កសិករទិញជីគីមីពីក្រុមហ៊ុនឯកជន និងពីឈ្មួញសុទ្ធតែខ្ចីលុយគេ ឬជំពាក់បំណុលគេដល់ពេលលក់ស្រូវយកលុយសងគេស្ទើរតែមិនគ្រប់ ។ រដូវប្រមូលផលស្រូវម្តងៗ កសិករលក់ស្រូវទៅប្រទេសវៀតណាមរាប់ម៉ឺនតោន ។ ដល់ពេលអស់ស្រូវហូបទើបទៅទិញអង្ករពីវៀតណាមមកវិញ ។ អង្ករវៀតណាមថ្លៃខ្ពស់ ហើយមានសារធាតុគីមីច្រើនទៀត ។ បញ្ហានេះធ្វើឱ្យប៉ះពាល់សុខភាពធ្ងន់ធ្ងរណាស់ ។ បច្ចុប្បន្ននេះសហគមន៍កសិករប្រចាំស្រុកដងទង់ បានសហការគ្នាក្នុងការបង្កើតធនាគារស្តុកស្រូវបាន២១កន្លែង សម្រាប់ជួយគ្នាដល់កសិករណាខ្វះខាតស្បៀងនាចុងរដូវដើម្បីជួយសង្គ្រោះការហូបចុក ។

លោកបណ្ឌិតកុមារ បានធ្វើការអំពាវនាវដល់រដ្ឋាភិបាលឱ្យពង្រីកជីសម្បទានសង្គមកិច្ចដាំដុះឱ្យបានច្រើនជាងការពង្រីកដីសម្បទានសេដ្ឋកិច្ច ។ បង្កើនការលើកទឹកចិត្តកុំឱ្យកសិករលក់ដីស្រែតទៅទៀត ។ ពង្រីកទីផ្សារ សហគមន៍ឱ្យបានច្រើនងាយលក់ផលិតផលដែលកសិករផលិតបាន ។ បង្កើន និងពង្រីកនូវសមត្ថភាពកសិករក្នុងការផលិតនិងទុកពូជស្រូវនៅតាមសហគមន៍ ។ មួល សម្បត្តិ